**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# ញត្តិគាំទ្រ

## សារពិសេសរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា លើការអនុវត្តកម្មវិធី និងគម្រោងក្រោមក្របខ័ណ្ឌ នៃតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV-DTA)

ក្នុងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មន្ត្រីការទូតនៅតាមបណ្ដាស្ថានតំណាងកម្ពុជានៅបរទេស យើងខ្ញុំទាំងអស់គ្នា សូមប្រកាសគាំទ្រយ៉ាងពេញទំហឹង ចំពោះសារពិសេស របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ លើការអនុវត្តកម្មវិធី និងគម្រោងក្រោមក្របខ័ណ្ឌនៃតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) ដែលជាគំនិតផ្ដួចផ្ដើមរបស់កម្ពុជាក្នុងឆ្នាំ១៩៩៩ ដែលពេលនោះមាន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ក្នុងគោលបំណងជំរុញសមាហរណកម្មខេត្តជាប់ព្រំដែននៃប្រទេសទាំងបី ដើម្បីប្រែក្លាយទៅជាព្រំដែនមិត្តភាព សាមគ្គីភាព និងការអភិវឌ្ឍ។ កិច្ចប្រជុំកំពូលនៃតំបន់ត្រីកោណអភិវឌ្ឍន៍នេះ ត្រូវបានធ្វើឡើងចំនួន ១១លើក រួចមកហើយ ដោយមានការប្ដូរវេនគ្នាធ្វើជាប្រធានរវាងប្រទេសទាំងបី ហើយឆ្នាំ២០២៤ នេះ កម្ពុជាគឺជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូល CLV លើកទី១២។

កិច្ចសហប្រតិបត្តិការនេះ មានគោលការណ៍គ្រឹះសំខាន់ក្នុងការលើកកម្ពស់ការគោរពគ្នា និងការជឿទុកចិត្តគ្នាទៅវិញទៅមក ដើម្បីផលប្រយោជន៍រួម ការការពារបូរណភាពទឹកដី និងការដោះស្រាយបញ្ហា តាមរយៈទំនាក់ទំនងការទូត និងច្បាប់អន្តរជាតិ។ ក្រោមគម្រោងកិច្ចសហប្រតិបត្តិការនេះ ប្រទេសទាំងបីបានសហការគ្នាយ៉ាងជិតស្និទ្ធ និងប្រកបដោយប្រសិទ្ធភាពក្នុងការឆ្លើយតបទៅនឹងការគំរាមកំហែងផ្នែកសន្តិសុខមិនប្រពៃណីដូចជា ឧក្រិដ្ឋកម្មឆ្លងដែន ការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន ការកាប់បំផ្លាញព្រៃឈើខុសច្បាប់ គ្រោះមហន្តរាយធម្មជាតិ និងសុខភាពសាធារណៈ ជាដើម។

ការថ្លែងសារពិសេសរបស់ **សម្ដេចតេជោ ប្រធានព្រឹទ្ធសភា** គឺជាការបង្ហាញឆន្ទៈដ៏មុតមាំ ប្រកបដោយគតិបណ្ឌិតក្នុងការបន្តចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិជាមួយរាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការបន្តអនុវត្តកម្មវិធី និងគម្រោងទាំងនេះ ដើម្បីជំរុញសមាហរណកម្មសេដ្ឋកិច្ច និងការតភ្ជាប់ ដែលនាំមកនូវសន្តិសុខ កំណើនពាណិជ្ជកម្មឆ្លងដែន និងវិស័យទេសចរណ៍ និងការកាត់បន្ថយភាពក្រីក្រតាមតំបន់ព្រំដែនផងដែរ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមប្រកាសថ្កោលទោស និងប្រឆាំងយ៉ាងដាច់អហង្ការ ចំពោះការញុះញង់បង្កចលាចល សំដៅបំផ្លាញសមិទ្ធផល និងដំណើរការអភិវឌ្ឍន៍នៃតំបន់ត្រីកោណអភិវឌ្ឍន៍ និងសូមអំពាវនាវដល់បងប្អូនជនរួមជាតិទាំងអស់ សូមបន្តចូលរួម និងគាំទ្រដល់ការអនុវត្តកម្មវិធី និងគម្រោងនៃតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) ដើម្បីជាឧត្តមប្រយោជន៍ជាតិមាតុភូមិ ជាពិសេសនៅក្នុងខេត្តជាប់ព្រំដែននៃប្រទេសទាំងបី។

ថ្ងៃសុក្រ ៦រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤

អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh